# ជំងឺសើរស្បែករបស់សត្វជ្រូក

# SKIN DISEASES OF THE PIG



រៀបរៀងឡើងដោយគណៈកម្មការផលិតកម្ម និងបសុព្យាបាលខេត្តតំបន់ពាយ័ព្យ

ឧបត្ថម្ភដោយអង្គការ យូអិនឌីភី/យូអិនអូភីអែស/ឃែរ៉េរ៉េ (UNDP/UNOPS/CARERE)

ថតចម្លងលើកទីមួយ; ខែមេសា ឆ្នាំ 1998

# ជំងឺសើស្បែករបស់សត្វជ្រូក និងហ្វាស្យូលីអាស៊ីស និងអាស្ការីយ៉ូស៊ីស

## មាតិការឿង


① ជំងឺរលាកស្បែកកូនជ្រូក ..... 01

② ជំងឺអុតជ្រូក ..... 05

③ ជំងឺអង្កែជ្រូក ..... 08

④ ជំងឺទន់ជើងរបស់សត្វជ្រូក ..... 18

⑤ ជំងឺងាប់ជាលិការបស់ជ្រូកមេ ..... 20

⑥ វិធីសាស្ត្រកុំអោយសត្វ (ធុះកគ្រោល) នៅពេលយើងត្រួតពិនិត្យ ឬព្យាបាលស្លាកស្នាម ឬដំបៅដែលកើតនៅលើស្បែក និងជើងរបស់សត្វជ្រូក ..... 22

ហ្វាស្យូលីអាស៊ីស

① ទំរង់ និងរូបរាង ..... 25

② វដ្តជីវិត ..... 27

③ ចលនាការបន្តជំងឺ ..... 32

④ រោគសញ្ញា ..... 34

⑤ បំរែបំរួលសរីរៈរោគ ..... 35

⑥ ការធ្វើរោគវិនិច្ឆ័យ ..... 36

⑦ ការព្យាបាល ..... 36

⑧ វិធានការការពារ ..... 39

<u>អាស្ការីយ៉ូស៊ីស</u>


① មូលហេតុនៃជំងឺ ..... 41
② ការកើតឡើងនៃជំងឺ ..... 41
③ ប្រភេទសត្វទទួលជំងឺ ..... 42
④ ការចំលងជំងឺ ..... 42
⑤ រោគសញ្ញា ..... 44
⑥ រោគសាស្ត្រ ..... 44
⑦ រោគវិនិច្ឆ័យ ..... 45
⑧ ការព្យាបាល ..... 45
⑨ ភាពស៊ាំ ..... 45
⑩ ការត្រួតពិនិត្យ ..... 46

** ឯកសារយោង
** ឈ្មោះគណៈកម្មការផលិតកម្ម និងបសុព្យាបាលខេត្តតំបន់ពាយ័ព្យ

# ជំងឺរលាកស្បែកកូនជ្រូក

# *(Bacterial Dermatoses Exudative Epidermitis)*

♦ <u>សណ្ឋានពាក្យ</u> : Greasy Pig Disease, Seborrhea aleosa, Exudative Dermatitis ។ នេះគឺជាប្រភេទជំងឺដែលមានការរលាកយ៉ាងធ្ងន់ធ្ងរលើស្បែកពាសពេញទាំងខ្លួន ដែលជាធម្មតាកើតនៅលើកូនជ្រូកដែលបៅដោះ និងចំពោះជ្រូកធំដោយគេពិនិត្យឃើញមានលក្ខណៈភ្លុំប៉ុ (មិនងាយជា) ។

❶ <u>មូលហេតុនៃជំងឺ</u> **(Aetiology) :**

ឥឡូវនេះគេចាត់ទុកថាជំងឺរលាកស្បែកគឺវាបណ្ដាលមកពី Bactery រួមមានប្រភេទ Micrococci sp. ឬ Strepto coccia ។

❷ <u>រោគសញ្ញា</u> **(Clinical Signs) :**

កូនជ្រូកកំពុងបៅដោះដែលមានអាយុពី 1-4 អាទិត្យ ងាយស្រួលក្នុងការឆ្លងជំងឺ ។ កូនជ្រូកជាច្រើនក្នុងសំបុកអាចកើតជំងឺក្នុងរយៈពេលតែមួយ ហើយអត្រាជំងឺឆ្លងមានការកើនឡើងពី 2-3 ក្បាល រហូតដល់ ស្លាប់អស់តែម្ដង ។ អត្រាស្លាប់ពី 20%-100% ។

Jones (1956) បាននិយាយថា គេមិនអាចថាជំងឺកើតឡើងដោយសារការធ្វើទ្រុង តាមរដូវ អនាម័យ ពូជ ភេទ ទំហំកូនជ្រូក ឬចំនួនកូនជ្រូកឡើយ នៅក្នុងកូនជ្រូកមួយសំបុកការកើតឡើងរបស់ជំងឺអាចមានលក្ខណៈភ្លាមៗ ហើយបង្ហាញនូវរោគសញ្ញាដំបូង គឺដោយសត្វមានសភាពអស់កម្លាំង ល្ហិតល្ហៃ មិនឃ្លានចំណី និង

ស្រកទឹក។ ដំបូងស្បែកឡើងស្រអាប់ និងគ្របដណ្ដប់ដោយក្រមីស្ងួត ហើយមានការរីករាលដាលនូវចំណុចពណ៌ក្រហមត្នោតយ៉ាងឆាប់រហ័ស (ទាំងទំហំ និងចំនួន) នៅលើសត្វខ្លះមានការរាលដាល Pustular (ពងខ្ទុះ) បន្ទាប់មកស្បែកឡើងមានជាតិសើមនិងប្រេងដែលជាលទ្ធផលនៃការរលាកខ្លាញ់នៃក្រពេញសេបូម (Greasy exudate of sebum) ។ ការរលាកមានការកើនឡើងនូវក្រមីក្រាស់ៗនៅលើស្បែកនឹងមានក្លិនគួរអោយខ្ពើមរអើម ។ នៅពេលក្រមីដាច់ចេញគេពិនិត្យឃើញនូវស្រទាប់ស្បែកដែលមានលក្ខណៈខ្ចី និងរលាកនៅខាងក្រោមជាញឹកញាប់ ជើងសត្វមានការសឹកដាច់សត្វខ្លះគេពិនិត្យ ឃើញនៅជុំវិញត្របកភ្នែកដែលបណ្ដាលអោយហើមនិងបើកមិនរួចសត្វគ្មានការ ទល់ណាមកទេតែសត្វខ្លះមានជំងឺរាគកើតមានឡើង ។ ក្នុងដំណាក់កាលនេះ (3-5 ថ្ងៃបន្ទាប់ពីចេញរោគសញ្ញាដំបូងនេះ) សត្វខ្លះមានការខ្វះជាតិទឹកនៅក្នុងខ្លួននិងចុះស្គមយ៉ាងខ្លាំង ហើយបន្ទាប់មកសត្វនោះនឹងស្លាប់ ។ ជំងឺនេះអាចកើតនៅលើជាលិកាមួយចំនួនទៀតនៃសត្វដូចជាតំរងនោម ដែលមានការពាក់ព័ន្ធដល់ឆ្អឹង ត្រគៀក តំរងនោម បំពង់នោម និងប្លោកនោម ។

ចំពោះសត្វដែលមានកើតជំងឺហើយអាចទ្រាំនឹងជំងឺនេះបានយូរ គេពិនិត្យឃើញក្រមីធំៗនៅពីលើស្បែកប្រេះជាចង្អូរបង្កើតជាស្នាមប្រេះយ៉ាងជ្រៅ សត្វទាំងនេះនឹងមានការហេវហត់យ៉ាងខ្លាំង និងស្លាប់ក្នុងរយៈពេល 2-3 ថ្ងៃ ក្រោយមក ឬក៏អាចមានសុខភាពទន់ខ្សោយ ប៉ុន្តែរោមត្រូវជ្រុះអស់ ។

លក្ខណៈរ៉ាំរ៉ៃ នៃជំងឺកើតមានឡើងលើកូនជ្រូកដែលមានអាយុច្រើនពី 6-10 សប្ដាហ៍ (L' Ecuyer, 1996) ហើយអាចមានរហូតដល់អាយុ 5 ខែ (Prercy, 1996) ។ តែទោះបីជាយ៉ាងណាក៏ដោយគេពិនិត្យឃើញថាគឺមានការ

កើតឡើងនូវជំងឺរបៀបនេះតិចតួចណាស់ ប្រសិនជាមានការគ្រប់គ្រងល្អក្នុងការចិញ្ចឹមជំងឺនេះអាចកើតមានឡើងទៅលើចំនួនជ្រូកយ៉ាងតិចបំផុត ។



❸ <u>ការព្យាបាល និងការត្រួតពិនិត្យ</u> **(Treatment and control) :**

នៅក្នុងដំណាក់កាលដំបូងត្រូវភេទថ្នាំ Antibiotics អាចបន្ថយនូវភាពធ្ងន់ធ្ងរនៃជំងឺ ។ គេអាចប្រើប្រាស់នូវប្រភេទថ្នាំ Antibiotics ដូចជា Penicilline,

Tetracyclines, Ampicillin Tylosin, Lincom-ycin និង Trimethoprimpotentiated, Sulphonamides នៅតាមមូលដ្ឋាន គេអាចព្យាបាលជំងឺដោយប្រើប្រភេទសាប៊ូប្រឆាំងបាក់តេរី (Antibacterial Soap) ឬក៏ថ្នាំការពារស្បែក ឧទាហរណ៍ : 0.5% នៃសូលុយស្យុង Sarlon ឬ Chloramine (Halamid) ឬក៏ប្រើដោយបាញ់ប្រភេទថ្នាំ Aerosol Antibiotic នៅលើកន្លែងដែលមានកើតជំងឺ ។

នៅពេលដែលមានជំងឺកើតកើតឡើងយើងគួរយកចិត្តទុកដាក់លើការអនាម័យ ជាពិសេសអនាម័យលើមេជ្រូកដែលមិនទាន់ផើម និងមេជ្រូកដែលផ្តាច់ដោះហើយ (Weaner) ការព្យាបាលត្រូវបង្កើននូវកំរិតវីតាមីន B ហើយមិនត្រូវអោយមានរបួសដល់ស្បែកសត្វដែលងាយធ្វើអោយកើតនូវជំងឺនេះ ។